ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០១៩ និងទស្សនវិស័យឆ្នាំ២០២០

រៀបចំដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹងថ្ងៃទី២ ខែមករា ឆ្នាំ២០២០

នៅឆ្នាំ២០១៩ សេដ្ឋកិច្ចពិភពលោកបានប្រឈមនឹងបញ្ហាមួយចំនួន ដែលបានបន្ថយកំណើន ទាំងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងលូតលាស់។ បញ្ហាប្រឈមចម្បង គឺភាពតានតឹងផ្នែកពាណិជ្ជកម្ម រវាងសហរដ្ឋអាមេរិកនិងចិន ដែលបានបន្ថយសកម្មភាពពាណិជ្ជកម្មអន្តរជាតិនិងការវិនិយោគ[១]។ បម្រែបម្រួលអាកាសធាតុបានគំរាមកំហែងដល់វិស័យកសិកម្ម និងជះឥទ្ធិពលដល់សេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ម៉្យាងទៀត បាតុភាពតវ៉ាបានកើតឡើងនៅក្នុងតំបន់មួយចំនួន[២] ដែលបង្កភាពមិនច្បាស់លាស់ទាំងផ្នែកនយោបាយនិងសេដ្ឋកិច្ច ស្របពេលការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) មិនទាន់សម្រេចបានកិច្ចព្រមព្រៀងជាក់លាក់នៅឡើយ។ ក្រៅពីនេះ ការរីកចម្រើនបច្ចេកវិទ្យាបានផ្តល់ជាកាលានុវត្តភាពផង និងជាបញ្ហាប្រឈមផង ចំពោះសេដ្ឋកិច្ច និងសង្គម ដូចជា ទៅលើការប្រើប្រាស់បច្ចេកវិទ្យាកាន់តែច្រើននៅក្នុងខ្សែសង្វាក់ផលិតកម្ម ទីផ្សារការងារ និងទំនាក់ទំនង។ បញ្ហាទាំងអស់នេះបានបង្កជាភាពមិនច្បាស់លាស់ដល់កំណើនសេដ្ឋកិច្ច នៅក្នុងប្រទេសនានានៅលើពិភពលោក។ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បណ្តាធនាគារកណ្តាលជាច្រើនបានអនុវត្តគោលនយោបាយរូបិយវត្ថុរិត្បិតកម្ម តាមរយៈការបន្ថយអត្រាការប្រាក់គោល ឬការចាក់បញ្ចូលសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ច។

ដោយឡែក សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៩ បន្តរីកចម្រើនរឹងមាំក្នុងអត្រា ៧,១% ដែលគាំទ្រដោយ៖ i/-កំណើននៃការនាំចេញ ជាពិសេសសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ធ្វើដំណើរ ii/-កំណើនក្នុងវិស័យសំណង់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ និង iii/-កំណើនក្នុងវិស័យទេសចរណ៍ ដោយកំណើនភ្ញៀវទេសចរបរទេស ជាពិសេសមកកាន់

[១] ប៉ុន្តែភាពតានតឹងពាណិជ្ជកម្មនេះក៏បានធ្វើឱ្យមានការបង្វែរទិសដៅវិនិយោគទៅកាន់ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ី ដូចជា វៀតណាម និងកម្ពុជា ជាដើម។
[២] បារាំង ហុងកុង ឥណ្ឌា អាមេរិកឡាទីន អ៊ីរ៉ាក់ ជាដើម។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

តំបន់ផ្សេងនិងក្នុងគោលបំណងធុរកិច្ច។ ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាបន្តទាក់ទាញការវិនិយោគផ្ទាល់បរទេស ជាពិសេស វិស័យហិរញ្ញវត្ថុ កម្មន្តសាល សំណង់និងអចលនទ្រព្យ និងវិស័យពាក់ព័ន្ធនឹងការស្នាក់នៅ។ គួរកត់សម្គាល់ថា កំណើនវិស័យកសិកម្មបន្តមានអត្រាទាបនិងបានថយចុះ ប៉ុន្តែក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចជារួមផងដែរ។

អតិផរណានៅឆ្នាំ២០១៩ មានកម្រិតជាមធ្យម ១,៩% ជាមួយនឹងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤.០៥៥ រៀលក្នុងមួយដុល្លារអាមេរិក ដែលបានរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ។ ទុនបម្រុងអន្តរជាតិបានបន្តកើនឡើងដល់ ១៨ ប៊ីលានដុល្លារអាមេរិក[៣] ដែលអាចធានាការនាំចូលទំនិញនិងសេវានៅគ្រាបន្ទាប់បានប្រមាណ ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមា (៣ខែ) ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលបានធ្វើឱ្យការចរាចរប្រាក់រៀលកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែដុល្លារូបនីយកម្មបន្តមានកម្រិតខ្ពស់ ដែលទាមទារការចូលរួមឱ្យបានទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។

ទន្ទឹមនេះវិស័យធនាគារមានសុខភាពល្អ និងបានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ គាំទ្រការរីកចម្រើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ក្រោមសុខសន្តិភាពនិងស្ថិរភាពនយោបាយដ៏រឹងមាំ។ ប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមាន ៧១% នៃប្រជាជនពេញវ័យសរុប ជាមួយនឹងកំណើនប្រាក់បញ្ញើ ២៥% និងប្រាក់កម្ចី ២៦%។ គួររំលេចថាកំណើនប្រាក់កម្ចីបានកើនឡើងមកវិញបន្ទាប់ពីបានថយចុះនារយៈពេលបីឆ្នាំកន្លងទៅ ប៉ុន្តែមិនទាន់ដល់កម្រិតក្នុងអំឡុងឆ្នាំ២០១០-២០១៥ (៣០%) ទេ។ កំណើនឡើងវិញនេះជំរុញជាចម្បងដោយកំណើនឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យ ការប្រើប្រាស់ និងពាណិជ្ជកម្ម។ ដោយសារការកើនឡើងនៃចំណូល តម្រូវការ និងភាពសម្បូរបែបនៃសេវាហិរញ្ញវត្ថុ ឥណទានសម្រាប់ការប្រើប្រាស់បានកើនឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចជា ឥណទានសម្រាប់ទិញទំនិញប្រើប្រាស់និងលំនៅឋានសម្រាប់ស្នាក់នៅ។ ឥណទានទាំងនេះបានជំរុញការប្រើប្រាស់ ដែលមានបច្ច័យវិជ្ជមានរួមចំណែកគាំទ្រកំណើនសកម្មភាពសេដ្ឋកិច្ច។ ទោះយ៉ាងណា ប្រសិនបើអ្នកប្រើប្រាស់មិនបានចំណាយឱ្យចំគោលដៅទេ នោះការកើនឡើងនៃឥណទានក៏អាចបង្កជាហានិភ័យផងដែរ។ម្យ៉ាងទៀត ប្រព័ន្ធធនាគារបានធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ដើម្បីគាំទ្រការរីកចម្រើនឥតឈប់ឈរនៃសេដ្ឋកិច្ចនិងសមាហរណកម្មទៅក្នុងតំបន់។ បច្ចុប្បន្ន ប្រជាជនប្រមាណ ៥ លាននាក់ កំពុងប្រើប្រាស់សេវាទូទាត់សងប្រាក់ប្រកបដោយភាពងាយស្រួល ឆាប់រហ័ស សុវត្ថិភាព និងតម្លៃសមរម្យ។ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍស្តង់ដារ QR Code និងដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធបាគងផ្អែកលើបច្ចេកវិទ្យា Blockchain សម្រាប់សម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការទូទាត់ឆ្លងដែន។

---

[៣] គិតតាមវិធីសាស្ត្រថ្មីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

នៅឆ្នាំ២០២០នេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា កំណើនសេដ្ឋកិច្ចពិភពលោក អាចកើនឡើងមកវិញ ដោយសារភាពតានតឹងពាណិជ្ជកម្មពិភពលោកអាចធូរស្រាល បន្ទាប់ពីការចរចារវាងសហរដ្ឋអាមេរិកនិងចិនបានចាប់ផ្តើមបង្ហាញសញ្ញាវិជ្ជមាន ហើយបញ្ហា Brexit ក៏អាចលេចឡើងនូវដំណោះស្រាយនាពេលខាងមុខ។ ទោះយ៉ាងណា ភាពមិនទាន់ច្បាស់លាស់នៅតែមាន ហើយសេដ្ឋកិច្ចពិភពលោកក៏អាចប្រឈមនឹងបញ្ហាផ្សេងទៀតរួមមាន៖ i/-ការរក្សាអត្រាការប្រាក់គោលឱ្យនៅកម្រិតទាបក្នុងរយៈពេលយូរ ក្រោមគោលនយោបាយរូបិយវត្ថុរិត្តារកម្មនៃធនាគារកណ្តាលប្រទេសធំៗ អាចគរពូនបំណុលក្នុងវិស័យឯកជននិងហានិភ័យខ្ពស់ចំពោះលំហូរមូលធនបញ្ច្រាសវិញពីប្រទេសកំពុងលូតលាស់ នៅពេលដែលការអនុវត្តគោលនយោបាយនេះនឹងត្រូវបញ្ចប់ ii/-បម្រែបម្រួលអាកាសធាតុនៅតែជាបញ្ហាប្រឈមប៉ះពាល់ដល់សេដ្ឋកិច្ចនិងសង្គម និង iii/-បញ្ហាភូមិសាស្ត្រនយោបាយ និងការបន្តបាតុភាពតវ៉ានៅក្នុងប្រទេសមួយចំនួន នៅតែជាបញ្ហាព្រួយបារម្ភចំពោះកំណើននៅតាមតំបន់។

ចំពោះកម្ពុជា សេដ្ឋកិច្ចអាចប្រឈមនឹងហានិភ័យមួយចំនួន។ ចំពោះហានិភ័យខាងក្រៅរួមមាន៖ i/-ការអាចថយចុះលឿនជាងការរំពឹងទុកនៃសេដ្ឋកិច្ចចិន ដែលអាចមានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយសេដ្ឋកិច្ចចិន និង ii/-និន្នាការនៃការអនុវត្តគោលនយោបាយគាំពារនិយមអាចប៉ះពាល់ដល់ការនាំចេញ។ ចំពោះហានិភ័យខាងក្នុងរួមមាន៖ i/-ការអាចបាត់បង់ការអនុគ្រោះពន្ធ "អ្វីៗគ្រប់យ៉ាងលើកលែងសព្វាវុធ (EBA)" ដែលអាចប៉ះពាល់ផ្ទាល់ដល់វិស័យកាត់ដេរសម្លៀកបំពាក់ និងវិស័យនានាក្នុងសេដ្ឋកិច្ចដែលទទួលផលដោយប្រយោលពីវិស័យកាត់ដេរ ii/-កម្រិតខ្ពស់នៃកំណើនឥណទានទៅកាន់វិស័យសំណង់អាចបង្កឱ្យហានិភ័យកើនឡើង នៅពេលដែលការផ្គត់ផ្គង់ក្នុងវិស័យអចលនទ្រព្យកើនឡើងខ្ពស់ហួសតម្រូវការ និង iii/-ការទិញផ្ទះដោយបង់រំលស់ពីក្រុមហ៊ុនអភិវឌ្ឍន៍សំណង់និងលំនៅឋាន មានភាពសកម្មនិងមិនទាន់មានការត្រួតពិនិត្យច្បាស់លាស់។

ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២០ ត្រូវបានរំពឹងថាអាចសម្រេចបានក្នុងរង្វង់ ៧% ជាមួយនឹងកម្រិតអតិផរណាប្រមាណ ២,៣%។ ការរំពឹងទុកនេះ ផ្អែកលើការព្យាករពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ដែលនឹងរួមចំណែកផ្តល់ភាពអំណោយផលដល់ការនាំចេញ វិនិយោគបរទេស និងវិស័យទេសចរណ៍កម្ពុជា ស្របពេលដែលសេដ្ឋកិច្ចទទួលបានលទ្ធផលជាលំដាប់ពីការធ្វើពិពិធកម្មមូលដ្ឋានកំណើន និងការកែទម្រង់ស៊ីជម្រៅសម្រាប់គាំទ្រដល់ការរីកចម្រើននៃសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការនាំចេញរំពឹងថានឹងបន្តមានកំណើនក្នុងអត្រាខ្ពស់ ពិសេសការនាំចេញទំនិញសម្រាប់ធ្វើដំណើរ ទំនិញកម្មន្តសាលផ្សេងៗ ទោះបីជាកំណើនការនាំចេញសម្លៀកបំពាក់អាចថមថយល្បឿនក៏ដោយ។ គួរបញ្ជាក់ថា ទោះបីជាសហភាពអឺរ៉ុបនឹងអាចសម្រេចដក EBA ពីកម្ពុជា នៅខែកុម្ភៈ ឆ្នាំ២០២០ ក៏ដោយ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជានៅតែរំពឹងថាបន្តមានកំណើន ដោយសារ៖ i/-យន្តការនៃការដក EBA ពេញលេញនឹងត្រូវអនុវត្តនៅ ៦ខែ

ក្រោយពីការសម្រេច, ii/-កម្ពុជានៅតែអាចនាំចេញទៅសហភាពអឺរ៉ុបបាន ទោះបីជា EBA ត្រូវបានដកក៏ដោយ ពីព្រោះការបាត់បង់ EBA គ្រាន់តែអាចបង្កើនថ្លៃទំនិញនាំចេញរបស់កម្ពុជាទៅសហភាពអឺរ៉ុប ដោយសារការដាក់ពន្ធក្នុងរង្វង់ ០,១% ទៅ ១២,៥% ទៅតាមប្រភេទទំនិញ ប៉ុន្តែប្រសិនបើតម្រូវការរបស់សហភាពអឺរ៉ុបមកលើទំនិញនាំចេញពីកម្ពុជានៅតែមាន នោះការនាំចេញរបស់កម្ពុជាទៅសហភាពអឺរ៉ុប ក៏នៅតែមានកំណើនផងដែរ ជាពិសេសក្រោយពីការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប ដោយសារទំនិញកម្ពុជានាំចេញទៅអង់គ្លេសមានចំនួន ២០% នៃការនាំចេញទៅសហភាពអឺរ៉ុប iii/-កំណើនប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា មិនទាន់មានផលប៉ះពាល់ទៅលើការប្រកួតប្រជែងរបស់កម្ពុជានោះទេ ដោយសារការបង្កើនមានលក្ខណៈសន្សឹមៗស្របពេលដែលផលិតភាពក៏បានកើនឡើងផងដែរ និង iv/-រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម, អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម, និងសម្រួលការធ្វើពាណិជ្ជកម្ម ព្រមទាំងបានអនុវត្តការកែទម្រង់ចាំបាច់នានា សំដៅបង្កើតបរិយាកាសកាន់តែអំណោយផលដល់ការវិនិយោគ ជំរុញផលិតកម្មក្នុងស្រុក និងលើកកម្ពស់ការធ្វើពិពិធកម្មផលិតផល និងទីផ្សារនាំចេញ ជាដើម។ កំណើនសេដ្ឋកិច្ចកម្ពុជាក៏នឹងត្រូវគាំទ្រដោយលំហូរវិនិយោគផ្ទាល់បរទេស ដែលរំពឹងថាបន្តមានកំណើនរឹងមាំ ជាមួយនឹងការបង្កើនការវិនិយោគនៃប្រទេសក្នុងតំបន់ ដែលអំណោយផលដោយសក្តានុពលនៃសេដ្ឋកិច្ចកម្ពុជា និងការបង្វែរទិសដៅវិនិយោគមកតំបន់អាស៊ីរួមមានកម្ពុជាផងដែរ។ វិស័យសំណង់និងអចលនទ្រព្យបន្តកើនឡើង ដែលឆ្លុះបញ្ចាំងដោយនិន្នាការកើនឡើងនៃការនាំចូលសម្ភារសំណង់ និងគម្រោងសាងសង់ដែលទទួលបានការអនុម័ត។ ភ្ញៀវទេសចរបរទេសបន្តកើនឡើងជាលំដាប់ ជាពិសេសមកកាន់តំបន់ឆ្នេរនិងក្នុងគោលបំណងធុរកិច្ច។ ទន្ទឹមនេះ តម្រូវការនិងការវិនិយោគក្នុងស្រុកបន្តកើនឡើងយ៉ាងរឹងមាំ ដែលរួមចំណែកជំរុញដោយកំណើនចំណូលរបស់ប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយវិត្តារកម្មថវិកា និងកំណើនឥណទាននៃវិស័យធនាគារនិងហិរញ្ញវត្ថុ។ ថ្មីៗនេះ គម្រោងសាងសង់នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិក៏បានអនុម័ត ហើយកំពុងអនុវត្ត ដែលបង្ហាញពីទស្សនទានវិជ្ជមានលើការប្រើប្រាស់របស់ប្រជាជនកម្ពុជា ជាពិសេសប្រជាជនមានចំណូលមធ្យម ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស។

# ឧបសម្ព័ន្ធ

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចនិងទំហំពាណិជ្ជកម្មពិភពលោក**

(ភាគរយ, ឆ្នាំ២០១៨ - ២០២០ព)




**ក្រាហ្វ ២ ៖ កំណើនសេដ្ឋកិច្ចប្រទេសធំៗ**

(ភាគរយ, ឆ្នាំ២០១៨ - ២០២០ព)




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ

**ក្រាហ្វ ៣ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(ឆ្នាំ២០០៤-២០២០ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤ ៖ និន្នាការនៃចំណែកតាមវិស័យចម្បងៗ**

(ឆ្នាំ២០០៤-២០១៩ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៥ ៖ ការនាំចេញតាមមុខទំនិញ និងកំណើនការនាំចេញ

(គិតជាលានដុល្លារអាមេរិក)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៦ ៖ ការនាំចេញមុខទំនិញសំខាន់ៗទៅទីផ្សារសំខាន់ៗ

(គិតជាលានដុល្លារអាមេរិក)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៧ ៖ ការនាំចេញកៅស៊ូ និងអង្ករ

(គិតជាលានដុល្លារអាមេរិក)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ៨ ៖ ការនាំចេញផលិតផលកម្មន្តសាលផ្សេងៗ

(គិតជាលានដុល្លារអាមេរិក)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ៩ ៖ ការនាំចូលតាមមុខទំនិញសំខាន់ៗ និងកំណើនការនាំចូលសរុប

(គិតជាលានដុល្លារអាមេរិក)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ១០ ៖ ការនាំចូលដែក ស៊ីម៉ង់ត៍ និងសម្ភារៈសំណង់ផ្សេងៗ




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា







ប្រភព៖ក្រសួងទេសចរណ៍ និងការគណនារបស់ធនាគារជាតិនៃម្ពុជា




**ក្រាហ្វ ១៥ ៖ ភ្ញៀវមកដល់កម្ពុជាតាមប្រទេស**

| ភ្ញៀវមកដល់កម្ពុជា | ចំនួនភ្ញៀវគិតជាលានអ្នក | | សមាមាត្រ ជាភាគរយ | | អត្រាកំណើនឆ្នាំលើឆ្នាំ | |
|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ប | ២០១៨ | ២០១៩ប | ២០១៨ | ២០១៩ប |
| ចិន | ២,០ | ២,៦ | ៣២,៦% | ៣៨,៦% | ៦៧,២% | ២៨,៥% |
| វៀតណាម | ០,៨ | ០,៩ | ១២,៩% | ១៣,៣% | -៤,២% | ១២,៣% |
| ថៃ | ០,៤ | ០,៤ | ៦,៩% | ៦,១% | -១៥,១% | -៤,០% |
| ឡាវ | ០,៤ | ០,៣ | ៦,២% | ៥,១% | -៣,២% | -៩,៦% |
| កូរ៉េខាងត្បូង | ០,៣ | ០,៣ | ៤,៩% | ៣,៩% | -១២,៦% | -១៣,៦% |
| សហរដ្ឋអាមេរិក | ០,៣ | ០,២ | ៤,០% | ៣,៧% | -២,២% | -១,០% |
| ជប៉ុន | ០,២ | ០,២ | ៣,៤% | ៣,១% | ៣,៥% | -០,៧% |
| ម៉ាឡេស៊ី | ០,២ | ០,២ | ៣,២% | ២,៩% | ១២,២% | -៣,៥% |
| បារាំង | ០,២ | ០,២ | ២,៨% | ២,៥% | -០,២% | -២,៤% |
| អង់គ្លេស | ០,២ | ០,២ | ២,៦% | ២,៤% | -២,៤% | ១,២% |
| ផ្សេងៗ | ១,៣ | ១,២ | ២០,៥% | ១៨,៤% | -៥,០% | -២,៣% |
| សរុប | ៦,២ | ៦,៧ | ១០០% | ១០០% | ១០,៧% | ៨,៧% |
| មិនរាប់បញ្ចូលភ្ញៀវចិន | ៤,២ | ៤,១ | ៦៧,៤% | ៦១,៤% | -៤,៩% | -០,៩% |

ប្រភព៖ក្រសួងទេសចរណ៍ និងការគណនារបស់ធនាគារជាតិនៃម្ពុជា

## ក្រាហ្វ ១៦ ៖ លំហូរទុនវិនិយោគផ្ទាល់បរទេសនៅកម្ពុជា

(គិតជាលានដុល្លារអាមេរិក)




## ក្រាហ្វ ១៧ ៖ លំហូរទុនវិនិយោគផ្ទាល់បរទេសបែងចែកតាមប្រទេស




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ១៨ ៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៧ - ខែធ្នូ ឆ្នាំ២០១៩)




## ក្រាហ្វ ១៩ ៖ អតិផរណាព្យាករណ៍

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, សម្រាប់ឆ្នាំ២០២០)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ២០ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក

(ខែមករា ឆ្នាំ២០១៥ - ខែតុលា ឆ្នាំ២០១៩)




## ក្រាហ្វ ២១ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក

(ឆ្នាំ២០០០ -២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២២ ៖ ទុនបម្រុងអន្តរជាតិ និងចំនួនខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់**

(ឆ្នាំ២០០៧- ២០១៩ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៣ ៖ រូបិយវត្ថុទូទៅ** ( M2 )

(គិតជាទ្រីលានរៀល ឆ្នាំ២០១០ - ឆ្នាំ២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៤ ៖ កំណើនឥណទាន និងកំណើនសេដ្ឋកិច្ច**

(គិតជាភាគរយ, ឆ្នាំ២០១០-២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ២៥ ៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
(ឆ្នាំ២០១២ -២០១៩)




### ក្រាហ្វ ២៦ ៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
(ឆ្នាំ២០១២ -២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ២៧ ៖ អនុបាតឥណទានមិនដំណើរការគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
(ឆ្នាំ២០១២ - ២០១៩)




### ក្រាហ្វ ២៨ ៖ ប្រភពទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
(ឆ្នាំ២០១៣ - ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ២៩ ៖ សន្ទនីយភាពនិងសាធនភាពរបស់គ្រឹះស្ថានធនាគារ
(ឆ្នាំ២០១២ - ២០១៩)




### ក្រាហ្វ ៣០ ៖ សន្ទនីយភាពនិងសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
(ឆ្នាំ២០១២ - ២០១៩)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៣១ ៖ ប្រាក់បង្វែរពលករពីបរទេស

(២០១៥ - ២០១៩ប)




ប្រភព ៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ក្រាហ្វ ៣២ ៖ កំណើនផលិតភាពកម្លាំងពលកម្ម




## ក្រាហ្វ ៣៣ ៖ ប្រាក់ឈ្នួលអប្បបរមា




ប្រភព៖ ceic data